00777311

E170

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២

**ជូនចំពោះ:** **ភាគីនៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង,មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារ (ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២)**

១. បន្ទាប់ពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងក្រៅផ្លូវការទៅភាគី កាលពីថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឯកសារ E167.1) និងផ្អែកលើព័ត៌មានទទួលបានពីភាគី អង្គជំនុំជម្រះសាលាដំបូងសូមផ្តល់ព័ត៌មានខាងក្រោមមុនពេលនៃការធ្វើសវនាការលើឯកសារដែលអង្គជំនុំជម្រះគ្រោងធ្វើចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២៖

*សវនាការទី ១៖ ឱកាសក្នុងការបញ្ជាក់អំពីឯកសារនានាដែលភាគីយល់ថាជាឯកសារពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាដែលជាវគ្គដំបូងនៃសវនាការ [ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២]*

២. ដូចដែលបានបញ្ជាក់ជូនកាលពីពេលមុន អង្គជំនុំជម្រះមានបំណងផ្តល់ឱកាសដល់ភាគីដើម្បីបង្ហាញឯកសារមួយចំនួនតូច ដែលភាគីយល់ថាជាឯកសារពាក់ព័ន្ធទៅនឹងប្រវត្តិបក្សកុម្មុយ

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 02 / 2012
ម៉ោង (Time/Heure) : 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

នីស្តកម្ពុជាដែលជាវគ្គដំបូងនៃសវនាការលើសំណុំរឿង០០២/០១។ សវនាការនេះមានគោលបំណងធ្វើយ៉ាងណាឲ្យសាធារណៈជនទទួលបានព័ត៌មានកាន់តែទូលំទូលាយ និងផ្តល់ឱកាសដល់ភាគីស្នើសុំដើម្បីបង្ហាញអង្គជំនុំជម្រះនូវឯកសារមួយចំនួនដែលភាគីយល់ថា ជាឯកសារសំខាន់សម្រាប់សវនាការវគ្គដំបូង ស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាក្នុងសំណុំរឿង ០០២/០១ នេះ។ នៅពេលភាគីលើកឯកសារណាមួយ ជនជាប់ចោទមានសិទ្ធិធ្វើអត្ថាធិប្បាយលើឯកសារនោះ ប្រសិនបើជនជាប់ចោទមានបំណងធ្វើដូច្នេះ។

៣. ដោយហេតុថាគោលបំណងសវនាការនេះ ខុសពីគោលបំណងនៃដំណើរការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងនោះ ភាគីអាចលើកឯកសារដែលបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះ (នោះគឺឯកសារប្រភេទ E3 ដែលមានស្រាប់) ឬឯកសារដែលភាគីធ្លាប់បានកំណត់ថាជាឯកសារពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះស្នើសុំឲ្យភាគីលើកឯកសារសំខាន់ៗតែត្រឹមមួយចំនួនតូចបានហើយ ដែលពាក់ព័ន្ធទៅនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងចែកជូនភាគី និងអង្គជំនុំជម្រះនូវបញ្ជីឯកសារដែលត្រូវបង្ហាញឲ្យបានមុនពេលសវនាការ និងជៀសវាងការបង្ហាញឯកសារដដែលៗ ដោយពុំត្រូវជ្រើសរើសយកឯកសារណា ដែលត្រូវបានលើកយកមកពិភាក្សាជាលម្អិតរួចហើយនៅក្នុងសវនាការដែលបានធ្វើរហូតមកដល់បច្ចុប្បន្ននេះ។

៤. អង្គជំនុំជម្រះសាលាដំបូងបែងចែកពេលវេលាចំនួន ២ ថ្ងៃកន្លះសម្រាប់គោលបំណងនេះ (ថ្ងៃច័ន្ទ ទី ១៣ ដល់ថ្ងៃ ពុធ ទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២) ទៅសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ដោយត្រូវមានការឯកភាពរវាងភាគីទាំងពីរទៅលើការបែងចែកពេលវេលា។ អង្គជំនុំជម្រះនឹងទុកពេលរសៀលថ្ងៃ ពុធ ទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ សម្រាប់មេធាវីការពារជនជាប់ចោទ នួន ជា។ ដោយហេតុថាសវនាការនេះពុំពាក់ព័ន្ធនឹងលទ្ធភាពនៃការទទួលយកឯកសារណាមួយ ដែលភាគីស្នើសុំដាក់មកអង្គជំនុំជម្រះ ទើបអង្គជំនុំជម្រះមិនបែងចែកពេលវេលាដល់ភាគីដទៃទៀតសម្រាប់ធ្វើការឆ្លើយតបទៅនឹងការបង្ហាញឯកសារទាំងនេះ។

*សវនាការទី ២៖ ឯកសារដែលត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង នៅមុនពេលសវនាការដំណាក់កាលបន្ទាប់ (ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ) [ថ្ងៃ ព្រហស្បតិ៍ ទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២]*

៥. ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់សវនាការដំណាក់កាលបន្ទាប់ អង្គជំនុំជម្រះនឹងផ្តល់ឱកាសដល់គ្រប់ភាគីក្នុងការលើកទឡ្ហីករណ៍តទល់ពាក់ព័ន្ធនឹងឯកសារទាំងឡាយណា ដែលមានយោងនៅត្រង់ជើងទំព័រនៃកថាខណ្ឌនានានៅក្នុងដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានកំណត់ថាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ (ដីកាដំណោះស្រាយ កថាខណ្ឌ ៣៣-១១២, កថាខណ្ឌ ៨៦៩-៨៧២, ៨៨០-៨៩២, ១០០១-១០១៥, ១១៣១-១១៤៤ និង ១១៤៧-១១៥០, *សូមមើល* អនុស្សរណៈ E155 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១១ ដូចដែលបានធ្វើវិសោធនកម្មកាលពីថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ ២០១២)។ ឯកសារដែលអង្គជំនុំជម្រះមិនពិចារណាគឺឯកសារក្នុងប្រភេទខាងលើដែលភាគីធ្លាប់បានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ (ឧបសម្ព័ន្ធ ក១-ក៥ នៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ (ឯកសារ E9/31) ត្រង់ចំណុចមានការបញ្ជាក់ថាជាឯកសារពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងនេះ (ឯកសារ E109/4)) និងសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលនឹងបង្កើតជាកម្មវត្ថុនៃសេចក្តីសម្រេចដែលស្ថិតក្រោមការពិចារណារបស់អង្គជំនុំជម្រះ។ ដើម្បីជាគំរូនោះ កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានចែកចាយតារាងឯកសារមួយចំនួនតូចដល់ភាគីនានាសម្រាប់លើកទឡ្ហីករណ៍តទល់ក្នុងអំឡុងពេលនៃសវនាការនេះ (ចាប់តាំងពីមានវិសោធនកម្មរបស់អង្គជំនុំជម្រះ ដើម្បីពិចារណាលើឯកសារដែលមានយោងនៅក្នុងកថាខណ្ឌនានា ដែលបានដាក់បន្ថែមក្នុងអនុស្សរណៈ E155)។

៦. អង្គជំនុំជម្រះសូមរម្លឹកអំពីសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួនចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ដែលនៅក្នុងសេចក្តីសម្រេចនោះអង្គជំនុំជម្រះបានសន្មតថាឯកសារដែលបានយោងនៅក្នុងដីកាដំណោះស្រាយជាឯកសារពាក់ព័ន្ធ និងអាចជឿជាក់បាន។ ហេតុដូច្នេះសវនាការនេះទុកឱកាសដល់ភាគីដែលមានបំណងជំទាស់នឹងការសន្មតខាងលើ ដោយលើកឡើងនូវ

00777314



មូលដ្ឋានសមស្របពាក់ព័ន្ធនឹងឯកសារជាក់លាក់ ដែលភាគីយល់ថាមិនបានបំពេញនូវលក្ខណៈវិនិច្ឆ័យដូចដែលមានចែងនៅក្នុងវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះផ្តល់ឱកាសឲ្យភាគីលើកការជំទាស់ដោយផ្ទាល់មាត់ ទៅនឹងឯកសារទាំងនេះ ជំនួសឲ្យការដាក់សារណាជាលាយលក្ខណ៍អក្សរ។

៧. អង្គជំនុំជម្រះបានកំណត់យកថ្ងៃ ព្រហស្បតិ៍ ទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ សម្រាប់គោលបំណងនេះ។ ដើម្បីសម្រួលដល់ការរៀបចំផែនការសវនាការ អង្គជំនុំជម្រះសូមស្នើទៅភាគីទាំងអស់ថាភាគីត្រូវជូនដំណឹងមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះយ៉ាងយូរបំផុតឲ្យបានត្រឹមថ្ងៃ ពុធ ទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ថាតើ ក) ភាគីមានបំណងជំទាស់ទៅនឹងឯកសារណាមួយដែលមានយោងនៅក្នុងកថាខណ្ឌ ៥ ដែរ ឬទេ និង ខ) ប្រសិនបើដូច្នេះ សូមបញ្ជាក់អំពីរយៈពេលដែលភាគីនីមួយៗត្រូវការសម្រាប់គោលបំណងនេះ។ បន្ទាប់មក អង្គជំនុំជម្រះនឹងធ្វើការបញ្ជាក់អំពីការបែងចែកពេលវេលាដល់ភាគី ដើម្បីលើកការជំទាស់ និងការឆ្លើយតបនៅពេលសមស្រប។

៨. ប្រសិនបើពេលវេលាអំណោយផលនោះ អង្គជំនុំជម្រះនឹងបន្តពិភាក្សាអំពីឯកសារទាំងប៉ុន្មានប្រភេទខាងក្រោមដែលភាគីបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ក្នុងករណីនេះ អង្គជំនុំជម្រះនឹងធ្វើការបែងចែកពេលវេលាសម្រាប់ភាគីនីមួយៗដោយផ្ទាល់មាត់នៅពេលក្រោយ។

> ឯកសារប្រភេទ A8- ឯកសារកំណត់ត្រាពាក់ព័ន្ធនឹងស្រុកត្រាំកក់៖ ឯកសារទាំងអស់នៅក្នុងឯកសារ E9/31.8 ដែលត្រូវបានរៀបរាប់ថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.8 (ឯកសារចំនួន ៥៧)
> ឯកសារប្រភេទ A17-ឯកសារស្តីពីការប្រាស្រ័យទាក់ទងជាលក្ខណៈអន្តរជាតិ៖ ឯកសារទាំងអស់ ក្នុងឯកសារ E9/31.17 ដែលត្រូវបានរៀបរាប់ថាជាឯកសារពាក់ព័ន្ធនៅក្នុងឯកសារ E109/4.17 (ឯកសារចំនួន ១៥៨)

៩. អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថាផ្ទុយពីអ្វីដែលមេធាវីការពារជនជាប់ចោទ ខៀវ សំផន បានលើកនៅក្នុងសំណើមួយរបស់ខ្លួន ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២

00777315

E170

(ឯកសារ E167.1) បានជូនដំណឹងជាមុនទៅភាគីអំពីសវនាការសម្រាប់សប្តាហ៍ក្រោយ និង បានស្នើសុំព័ត៌មានពីពួកគេនៅមុនពេលអង្គជំនុំជម្រះចេញអនុស្សរណៈនេះ។ ហេតុដូច្នេះ អនុស្សរណៈនេះគឺជាការកំណត់កាលបរិច្ឆេទជាផ្លូវការសម្រាប់សវនាការនៅសប្តាហ៍ក្រោយ និងជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើ E167។